**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០៦៣/២៤ ន.គ.ស/សរ.ស.ណ.

ថ្ងៃ ចន្ទ ៨ រោច ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ គ.ស ២០២៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារពេលបន្ថែមអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា លេខ ១៧ "កិច្ចសន្យាធានារ៉ាប់រង" និង លេខ ៩ "ឧបករណ៍ហិរញ្ញវត្ថុ" សម្រាប់ក្រុមហ៊ុនធានារ៉ាប់រង

អនុលោមតាមប្រកាសលេខ ០៦៨ សហវ.ប្រក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា, សេចក្តីជូនដំណឹងលេខ ០៩៧/០៩ សហវ-ក.ជ.គ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS), ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs), សេចក្តីជូនដំណឹងលេខ ០០១២/២៣ ន.គ.ស. /ស.ជ.ណ. ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ និងយោងការចាំបាច់, និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សូមជូនដំណឹងដល់ លោក/លោកស្រី ប្រធានក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ដែលកំពុងធ្វើប្រតិបត្តិការផ្តល់សេវាធានារ៉ាប់រងគ្រប់ប្រភេទឱ្យបានជ្រាបថា៖

១. **ន.គ.ស.** សម្រេច <u>ពន្យារពេលបន្ថែមក្នុងការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា លេខ ១៧ (CIFRS 17) *"កិច្ចសន្យាធានារ៉ាប់រង"* និង លេខ ៩ (CIFRS 9) *"ឧបករណ៍ហិរញ្ញវត្ថុ"* សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងនៅកម្ពុជា រហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ ២០២៨</u>។

២. ក្រុមហ៊ុនធានារ៉ាប់រងដែលទទួលយកការពន្យារពេលនេះ ត្រូវផ្តល់ជូន **ន.គ.ស.** នូវរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស ដោយគិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ ហើយត្រូវបញ្ជូនរបាយការណ៍វឌ្ឍនភាពប្រចាំឆមាសមក **ន.គ.ស.** យ៉ាងយូរ ១៥ ថ្ងៃគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ឆមាសនីមួយៗ។

៣. ក្នុងអំឡុងនៃការពន្យារ ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបន្តប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ដែលមានការពាក់ព័ន្ធជាធរមាន។

ការមិនគោរពតាមសេចក្តីជូនដំណឹងនេះ ត្រូវចាត់ទុកថាជាអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

អាស្រ័យហេតុនេះ សូម លោក/លោកស្រី ប្រធានក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ ជ្រាបជាព័ត៌មាន និងត្រូវអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**អគ្គនាយក**

**ចៅ ចារិន**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ០៨៥ - ២៣ ៨៨២ ១១១
Phone: 023 882 111